**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

# របាយការណ៍ស្តីពី
# ការចូលរួមចំណែករបស់កម្ពុជា
# ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ
# ស្តីពីប្រែប្រួលអាកាសធាតុ

**ឆ្នាំ ២០១៥**

# មាតិកា


**សេចក្តីផ្តើម** ........ 1

**១. បរិបទជាតិ** ........ 3

**២. ការបន្សាំ** ........ 4

២.១ ភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ ........ 4

២.២ សកម្មភាពជាអាទិភាព ........ 6

**៣. ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់** ........ 7

៣.១ ការរួមចំណែក ........ 7

ការរួមចំណែករបស់កម្ពុជា ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មានលក្ខណៈស្របគ្នាទៅនឹងលក្ខខណ្ឌមួយចំនួននៃសេចក្តីអំពាវនាវរបស់ទីក្រុង លីម៉ា (Lima Call for Action) កថាខ័ណ្ឌទី១១ ដែលមានខ្លឹមសារដូចខាងក្រោម៖ ........ 7

៣.២ ព័ត៌មានដើម្បីផ្ទៀងផ្ទាត់អំពីសុក្រឹតភាព តម្លាភាព និងការយោគយល់ ........ 10

៣.៣ ភាពត្រឹមត្រូវ និងមហិច្ឆិតា ........ 12

**៤. ដំណើរការរៀបចំផែនការនិងការអនុវត្ត** ........ 13

**៥. មធ្យោបាយនៃការអនុវត្ត** ........ 16

**ឧបសម្ព័ន្ធ៖** ព័ត៌មានបន្ថែម ដែលពាក់ព័ន្ធនឹងយុទ្ធសាស្រ្ត និងគោលនយោបាយ ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ........ 18

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## របាយការណ៍ស្តីពី
## ការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីប្រែប្រួលអាកាសធាតុ

### សេចក្តីផ្តើម

កម្ពុជាទទួលស្គាល់ពីតម្រូវចាំបាច់ក្នុងការគោរពគោលការណ៍នានានៃអនុសញ្ញា ក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ជាពិសេស "គោលការណ៍ទទួលខុសត្រូវរួម ប៉ុន្តែក្នុងកម្រិតដោយឡែកពីគ្នា និងទៅតាមសមត្ថភាពរៀងៗខ្លួន" និងសិទ្ធិរបស់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការអភិវឌ្ឍដោយចីរភាព។ ការកំហិតជាសកលក្នុងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក៏ជាការចាំបាច់ផងដែរ ដើម្បីសម្រេចបានគោលដៅចុងក្រោយនៃអនុសញ្ញានេះ *"ដើម្បីរក្សាតុល្យភាពនៃកំហាប់ឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាសនៅកម្រិតដែលអាចទប់ស្កាត់ការរំខានប្រកបដោយគ្រោះថ្នាក់នៃសកម្មភាពមនុស្សមកលើប្រព័ន្ធអាកាសធាតុ"*[1]។ ជាការឆ្លើយតបនឹង "ការអំពាវនាវឱ្យមានសកម្មភាពទីក្រុង លីម៉ា" កម្ពុជាសូមដាក់ជូននូវរបាយការណ៍ស្តីពីការចូលរួមចំណែករបស់ខ្លួន (INDC) ដើម្បីអនុវត្តអនុសញ្ញា UNFCCC នៅមុនសន្និសីទបណ្តាភាគីនៃអនុសញ្ញា UNFCCC លើកទី២១ (COP21) នៅក្រុងប៉ារីស នាខែធ្នូ ឆ្នាំ២០១៥។ របាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC នេះនឹងអាចកែសម្រួល ដើម្បីឆ្លើយតបនឹងស្ថានភាពជាតិនៅពេលកម្ពុជាបន្តមាគ៌ា នៃការអភិវឌ្ឍរបស់ខ្លួន។

កម្ពុជា ជាប្រទេសដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិច ប៉ុន្តែងាយរងគ្រោះជាខ្លាំងនៅចំពោះមុខផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។

[1] សេចក្តីសម្រេច UNFCCC -/CP.20
https://unfccc.int/files/meetings/lima_dec_2014/application/pdf/auv_cop20_lima_call_for_climate_action.pdf

ដូច្នេះ ការចូលរួមចំណែករបស់កម្ពុជា ត្រូវតែស្របទៅតាមអាទិភាពនៃការអភិវឌ្ឍរបស់ខ្លួន។ របាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញា UNFCCC បានដាក់បញ្ចូលទាំងសកម្មភាពបន្សាំ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដោយផ្អែកលើស្ថានភាពរបស់ជាតិ។

របាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC ចែកចេញជា ប្រាំផ្នែក៖

- ផ្នែកទី១៖ រៀបរាប់អំពីបរិបទជាតិដែលបង្ហាញពីស្ថានភាពទូទៅទាក់ទងនឹងរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC
- ផ្នែកទី២៖ មានព័ត៌មានស្តីពីការបន្សាំ ដែលរៀបរាប់អំពីភាពងាយរងគ្រោះរបស់កម្ពុជា ដោយសារការប្រែប្រួលអាកាសធាតុ និងសកម្មភាពបន្សាំជាអាទិភាព
- ផ្នែកទី៣៖ ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលបញ្ជាក់អំពីការរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញា UNFCCC ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ជាមួយព័ត៌មានដែលធានាបាននូវភាពច្បាស់លាស់ តម្លាភាព ការយោគយល់ និងការពិចារណាពីភាពត្រឹមត្រូវ និងមហិច្ឆិតានៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
- ផ្នែកទី៤៖ គឺជាដំណើរការរៀបចំផែនការនិងការអនុវត្ត ដែលបញ្ជាក់អំពីស្ថាប័ន គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការនានា ដែលនឹងទ្រទ្រង់ដល់ការអនុវត្តសកម្មភាពស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC
- ផ្នែកទី៥៖ មធ្យោបាយអនុវត្ត ជាមួយព័ត៌មានអំពីការគាំទ្រដែលចាំបាច់សម្រាប់ការអនុវត្តការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញា UNFCCC។

កម្ពុជាជឿជាក់ថា តាមរយៈរបាយការណ៍ស្តីពីការចូលរួមចំណែករបស់ខ្លួន ដើម្បីអនុវត្តអនុសញ្ញា UNFCCC ដែលជាអភិក្រមថ្មីមួយ " ផ្តើមចេញពីប្រទេសនីមួយៗ" សម្រាប់ដោះស្រាយការប្រែប្រួលអាកាសធាតុ យើងនឹងអាចជំនះភាពទ័លច្រកក្នុងការចរចា ដូចដែលបានជួបប្រទះក្នុងបណ្តាឆ្នាំកន្លងមកនេះ។ កម្ពុជាក៏សង្ឃឹមផងដែរថា កិច្ចព្រមព្រៀងថ្មីដែលនឹងត្រូវអនុម័តក្នុងសន្និសីទបណ្តាភាគីនៃអនុសញ្ញា UNFCCC លើកទី២១ នៅក្រុងប៉ារីស នឹងទទួលជោគជ័យក្នុងការកំណត់សីតុណ្ហភាពនៅត្រឹម កម្រិតដែលអាចទប់ស្កាត់ការរំខានប្រកបដោយគ្រោះថ្នាក់ នៃសកម្មភាពមនុស្សមកលើប្រព័ន្ធអាកាសធាតុពិភពលោក និងទន្ទឹមនឹងនេះរួមចំណែកកាត់បន្ថយភាពក្រីក្រលើពិភពលោកនិងជំរុញកិច្ចប្រឹងប្រែង អភិវឌ្ឍន៍សេដ្ឋកិច្ចផងដែរ។

# ១. បរិបទជាតិ

កម្ពុជា ជាប្រទេសដែលងាយរងគ្រោះជាខ្លាំងដោយសារផលវិបាកនានា ដែលបណ្តាលមកពីប្រែប្រួលអាកាសធាតុ ជាពិសេសគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងការជ្រាបចូលនៃទឹកប្រៃ។ កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ព្រៃឈើ សុខភាពមនុស្ស និងតំបន់ឆ្នេរ គឺជាវិស័យដែលរងគ្រោះខ្លាំងបំផុតដោយសារប្រែប្រួលអាកាសធាតុ។ អាទិភាពអភិវឌ្ឍន៍ជាតិសំខាន់ៗរបស់កម្ពុជា ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) សម្រាប់ឆ្នាំ២០១៤-២០១៨ គឺការកាត់បន្ថយភាពក្រីក្រ ទន្ទឹមនឹងការពង្រឹងកំណើនសេដ្ឋកិច្ចតាមអត្រាថេរ៧-៨% ក្នុងមួយឆ្នាំ[2]។ កម្ពុជាមានបំណងឈាន ពីប្រទេសអភិវឌ្ឍន៍តិចតួច (LDC) ទៅជាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានចំណូលកម្រិតទាបមធ្យម នៅឆ្នាំ២០១៨ និងខ្ពស់មធ្យមនៅឆ្នាំ២០៣០។ គោលដៅនេះនឹងអាចសម្រេចបានតាមរយៈពិពិធកម្មសេដ្ឋកិច្ច ដែលរួមទាំងឧស្សាហូបនីយកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

កិច្ចប្រឹងប្រែងនានាក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា មិនអាចកាត់ផ្តាច់ចេញពីគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច និងគោលដៅកាត់បន្ថយភាពក្រីក្របានឡើយ។ វិស័យកសិកម្មត្រូវបានរំពឹងថានឹងកើនឡើងតាមអត្រា៥% ក្នុងមួយឆ្នាំ ដើម្បីឈានដល់ចំណុចដៅនៃកំណើនសេដ្ឋកិច្ចជាតិ និងការនាំចេញ ក៏ដូចជាដើម្បីរួមចំណែកបំពេញតម្រូវការសន្តិសុខស្បៀងរបស់ប្រជាជនផងដែរ។ ទន្ទឹមនឹងនេះ កម្ពុជាមានគម្របព្រៃឈើច្រើនជាង៥៧% ហើយរាជរដ្ឋាភិបាលកំពុងបន្ត ប្រឹងប្រែងក្នុងការបង្កើន និងរក្សាអត្រានេះ ដើម្បីជានាវបរចិញ្ចឹមជីវិតសម្រាប់សហគមន៍ដែលពឹងផ្អែក លើព្រៃឈើ និងសម្រាប់មនុស្សជំនាន់ក្រោយៗផងដែរ។ ពិតមែនតែសម្ពាធលើធនធាន និងដីធ្លីមានកម្រិតខ្ពស់ក្តី ក៏សារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ ចុងក្រោយបានបង្ហាញថា កម្ពុជានៅជាប្រទេសអាងស្តុកកាបូននៅឡើយ នៅឆ្នាំ២០០០[3]។

ទោះបីមានការប្រឈមជាច្រើន ដែលពាក់ព័ន្ធជាមួយមហិច្ឆិតាខ្លាំងក្លាទាំងនេះក៏ដោយ កម្ពុជាមានមោទនភាពចំពោះវឌ្ឍនភាព ដែលសម្រេចបានលើការរៀបចំគោលនយោបាយប្រែប្រួលអាកាសធាតុ ជាពិសេសចាប់តាំងពីការចូលជាសមាជិកនៃអនុសញ្ញា UNFCCC នៅឆ្នាំ១៩៩៦។ កិច្ចខិតខំប្រឹងប្រែងនានាត្រូវបានអនុវត្តតាមរយៈការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ឧទាហរណ៍ កម្ពុជាបានរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៤-២០២៣ (ផ.យ.ប.អ.ក.) និងបណ្តាផែនការសកម្មភាពដែលបានរៀបចំឡើងដោយក្រសួងពាក់ព័ន្ធ។ ផែនការទាំងនេះគឺជាឯកសារគោលនយោបាយជាតិពេញលេញដំបូងបង្អស់របស់កម្ពុជា ដែលមិនត្រឹមតែបង្ហាញអំពីតម្រូវការបន្សាំ ជាអាទិភាពរបស់ប្រទេសនេះ

---

[2]ប្រភព៖ RGC (2014), National Strategic Development Plan 2014-18, Ministry of Planning. Available at: http://www.mop.gov.kh/Home/NSDP/NSDP20142018/tabid/216/Default.aspx

[3]យោងតាមសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ចុងក្រោយបង្អស់សម្រាប់ឆ្នាំ២០០០នៅក្នុង៖ RGC (2015), Second National Communication to the UNFCCC, Ministry of Environment (unpublished)

ប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តល់ជាផែនទីបង្ហាញផ្លូវ សម្រាប់កាត់បន្ថយការបញ្ចេញកាបូនពីវិស័យសេដ្ឋកិច្ចសំខាន់ៗ និងការពង្រីកអាងស្តុកកាបូនផងដែរ។ លើសពីនេះ កម្ពុជាបានរៀបចំគោលនយោបាយ និងផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតង ដែលកំណត់មាគ៌ាសម្រាប់ជំរុញសេដ្ឋកិច្ចតាមរយៈជម្រើសការបញ្ចេញកាបូនតិច ការសន្សំសំចៃ និងការបង្កើតការងារ ការពារក្រុមជនងាយរងគ្រោះ និងលើកកម្ពស់ចីរភាពបរិស្ថាន។

កម្ពុជាក៏សម្រេចបាននូវវឌ្ឍនភាពច្រើនផងដែរ ក្នុងការធ្វើសមាហរណកម្មបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងគម្រោងថវិកា តាមរយៈការរៀបចំក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ការពិនិត្យជាទៀងទាត់នូវការចំណាយសាធារណៈលើការងារអាកាសធាតុ និងបានកែលម្អការឃ្លាំមើលហិរញ្ញវត្ថុអាកាសធាតុនៅក្នុងកម្រងទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA)។ នៅក្នុងវិស័យជាអាទិភាពនានា មានការងារដែលកំពុងអនុវត្តដើម្បីកែលម្អឯកសារថវិកា ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងនៅក្នុងការធ្វើសមាហរណកម្មការប្រែប្រួលអាកាសធាតុទៅក្នុងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ។ កម្មវិធីសិក្សាហិរញ្ញវត្ថុអាកាសធាតុក៏កំពុងត្រូវបានដាក់បញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលអំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ ដែលបានរៀបចំឡើងសម្រាប់មន្ត្រីរដ្ឋាភិបាល។

# ២. ការបន្សាំ

## ២.១ ភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ

កម្ពុជា គឺជាប្រទេសមួយដែលស្ថិតក្នុងចំណោមបណ្តាប្រទេសដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុនៅក្នុងពិភពលោក[4]។ ក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួចមួយដែលពឹងផ្អែកលើវិស័យកសិកម្ម កម្ពុជាងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ ជាចម្បងដោយសារតែលក្ខខណ្ឌភូមិសាស្ត្ររបស់ខ្លួន ការពឹងផ្អែកលើវិស័យកសិកម្ម និងសមត្ថភាពបន្សាំនៅមានកម្រិតទាប រួមទាំងធនធានហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្សមានកម្រិតកំណត់។ ក្នុងទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានជួបប្រទះគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះកាន់តែញឹកញាប់ និងធ្ងន់ធ្ងរ ដែលបង្កជាការប្រឈមធ្ងន់ធ្ងរចំពោះការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។ ខ្យល់ព្យុះកំពុងកើតឡើងកាន់តែញឹកញាប់ និងបង្កផលប៉ះពាល់កាន់តែខ្លាំងឡើងចំពោះហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសេដ្ឋកិច្ច ជាពិសេសនៅតាមទីជនបទ។ ជាឧទាហរណ៍ការធ្លាក់ភ្លៀងខ្លាំងនៅខែតុលាឆ្នាំ២០១៣ បាននាំមកនូវទឹកជំនន់យ៉ាងគំហុក ដែលបង្កផលប៉ះពាល់លើប្រជាជនជនច្រើនជាងកន្លះលាននាក់។ ខេត្តចំនួនច្រើនជាងពាក់កណ្តាលនៅកម្ពុជាបានរងផលប៉ះពាល់ ហើយតំបន់មេគង្គទាំងមូលបានរងនូវផលប៉ះពាល់ ជាពិសេសនៅពេលដែលកំពស់ទឹកទន្លេនេះបានកើនឡើងរួមជាមួយជំនន់ទឹកភ្លៀង។

[4]ប្រភព: RGC (2012), RGC (2006) and RGC (2015), Second National Communication to the UNFCCC, Ministry of Environment (unpublished)

ការប៉ាន់ប្រមាណមួយបានបង្ហាញថាទំហំនៃការខូចខាត និងការបាត់បង់ដែលបង្កដោយទឹកជំនន់ឆ្នាំ២០១៣ មានប្រហែលជា៣៥៦លានដុល្លារអាមេរិក[5] ក្នុងនោះ១៥៣លានដុល្លារអាមេរិក ជាការខូចខាតចំពោះហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅក្នុងតំបន់រងគ្រោះ និង២០៣លានដុល្លារអាមេរិក ជាការបាត់បង់ផលិតផល និងចរន្តសេដ្ឋកិច្ច។ ដូចគ្នានេះដែរនៅឆ្នាំ២០១២ គ្រោះរាំងស្ងួតបានកើតមានចំនួនក្នុង១១ខេត្ត ក្នុងចំណោមខេត្តសរុប២៤ នៅកម្ពុជា ហើយបានបង្កការខូចខាតចំពោះដំណាំស្រូវជាច្រើនពាន់ហិកតា។

ម៉ូដែលឧតុនិយមបានព្យាករថា សីតុណ្ហភាពនឹងកើនឡើងនៅពេលអនាគត បូកបន្ថែមពីលើទឹកជំនន់ធ្ងន់ធ្ងរ ដែលកើតមានឡើងកាន់តែញឹកញាប់ ដូចដែលបានជួបប្រទះក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ របបទឹកភ្លៀងនឹងកាន់តែមិនអាចព្យាករណ៍បានរហូតដល់ឆ្នាំ២០៥០។ កសិកម្ម ព្រៃឈើ ហេដ្ឋារចនាសម្ព័ន្ធ សុខភាពមនុស្ស និងតំបន់ឆ្នេរ គឺជាវិស័យដែលងាយរងគ្រោះបំផុតបណ្តាលមកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ៖

- កសិកម្ម៖ ប្រព័ន្ធផលិតកម្មកសិកម្មជាច្រើនរបស់កម្ពុជាពឹងផ្អែកលើទឹកភ្លៀង ឬទឹកជំនន់ទន្លេ និងការស្រកចុះប្រចាំឆ្នាំនៃទឹកបឹងទន្លេសាប ដូច្នេះប្រព័ន្ធបែបនេះងាយរងគ្រោះបណ្តាលមកពីការប្រែប្រួលអាកាសធាតុប្រចាំទី និងរបបខ្យល់មូសុង

- ហេដ្ឋារចនាសម្ព័ន្ធ៖ ការកើតឡើងកាន់តែញឹកញាប់ និងធ្ងន់ធ្ងរ នៃទឹកជំនន់ ដោយសារប្រែប្រួលអាកាសធាតុ តម្រូវឱ្យមានការចំណាយកាន់តែខ្ពស់លើការថែទាំនិងការកែលម្អផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធស្រោចស្រព។ នេះជាករណីជាក់ស្តែងដែលកើតឡើងនៅតាមទីប្រជុំជន ដែលមានការប្រមូលផ្តុំកាន់តែច្រើនឡើងនូវចំនួនប្រជាជន និងទ្រព្យសម្បត្តិ

- វិស័យព្រៃឈើ៖ នៅក្រោមសេណារីយ៉ូការបញ្ចេញឧស្ម័ន SRESB1 និង SRESA2 បានបង្ហាញថា រហូតដល់ឆ្នាំ២០៥០ ព្រៃឈើភាគច្រើននៅតំបន់វាលទំនាបនឹងជួបប្រទះភាពរាំងស្ងួតមានរយៈពេលកាន់តែវែង ជាពិសេសព្រៃឈើនៅភាគឦសាន និងភាគនិរតី។ ព្រៃឈើច្រើនជាង៤លានហិកតានៅក្នុងតំបន់វាលទំនាប ដែលបច្ចុប្បន្ននេះខ្សត់ទឹកមានរយៈពេលពី៤ទៅ៦ខែ នឹងកាន់តែខ្សត់ទឹកឡើងមានរយៈពេលកាន់តែវែងពី៦ ទៅ៨ខែ ឬវែងជាងនេះ

- សុខភាពមនុស្ស៖ ការប្រែប្រួលអាកាសធាតុអាចមានផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល។ ជាឧទាហរណ៍នៃផលប៉ះពាល់ដោយផ្ទាល់ រួមមានការបាត់បង់ជីវិត រងរបួស ប៉ះពាល់ស្មារតី និងការខូចខាហេដ្ឋារចនាសម្ព័ន្ធសុខភាពសាធារណៈ។ ឧទាហរណ៍នៃផលប៉ះពាល់ដោយប្រយោល រួមមានការប្រែប្រួលវិសាលភាពភូមិសាស្ត្រ និងគ្រោះថ្នាក់នៃជំងឺបង្កឡើងពីមេរោគ ជំងឺចម្លងតាមទឹក ជំងឺឆ្លងកង្វះអាហារូបត្ថម្ភ និងភាពអត់ឃ្លាន ដែលជាលទ្ធផលនៃការរំខានចំពោះប្រព័ន្ធអេកូឡូស៊ី

[5] Cambodia 2013:Post-Flood Early Recovery Need Assessment Report, RGC.

- តំបន់ឆ្នេរ៖ ធនធានក្នុងតំបន់ឆ្នេរបានប្រឈមរួចមកហើយនូវសម្ពាធមួយចំនួន ដែលរួមមានការនេសាទហួសកម្រិត ការធ្វើអាជីវកម្មហួសកម្រិតលើធនធានព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង ដែលនាំឱ្យមានកំណើនការហូរច្រោះដី។ ការប្រែប្រួលអាកាសធាតុបានបូកបន្ថែមឥទ្ធិពលលើបញ្ហាប្រឈមនានាដែលមានស្រាប់ ដោយសារកំណើននីវ៉ូទឹកសមុទ្រ ការថយចុះដីដាំដំណាំ និងការថយចុះវត្តមានទឹកស្អាត។

២.២ សកម្មភាពជាអាទិភាព

ការបន្សាំទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន និងទៅអនាគត គឺជាអាទិភាពមួយសម្រាប់កម្ពុជា។ កម្ពុជាជឿជាក់ថា សកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុទាមទារឱ្យមានអភិក្រមចម្រុះពហុវិស័យ ដែលមានប្រសិទ្ធភាព និងដែលអាចគាំទ្រដល់គោលដៅអភិវឌ្ឍន៍របស់ជាតិ។

កម្ពុជា បានជ្រើសយកសកម្មភាពអាទិភាពមួយចំនួនដោយផ្តោតលើសកម្មភាពនានា ដែលផ្តល់សហប្រយោជន៍ជាមួយនឹងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ រួមមានដូចតទៅ៖

- លើកកម្ពស់ និងបង្កើនសមត្ថភាពបន្សាំរបស់សហគមន៍នានា ជាពិសេសតាមរយៈសកម្មភាពបន្សាំផ្អែកលើសហគមន៍ និងការស្តារប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- ការអនុវត្តវិធានការគ្រប់គ្រងនានាសម្រាប់តំបន់ការពារធម្មជាតិ ដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- ការពង្រឹងប្រព័ន្ធប្រកាសផ្តល់ព័ត៌មានជាមុន និងការផ្សព្វផ្សាយព័ត៌មានអំពីអាកាសធាតុ
- ការសាងសង់ និងជួសជុលទំនប់ការពារទឹកជំនន់សម្រាប់វិស័យកសិកម្ម និងការអភិវឌ្ឍទីប្រជុំជន
- បង្កើនការប្រើប្រាស់ស្ថានីយ៍បូមទឹកចល័ត និងស្ថានីយ៍អចិន្ត្រៃយ៍ នៅក្នុងការឆ្លើយតបទៅនឹងភាពរាំងស្ងួតក្នុងកូនរដូវប្រាំង និងជំរុញការស្រាវជ្រាវទឹកក្រោមដីនៅក្នុងការឆ្លើយតបនឹងគ្រោះរាំងស្ងួត និងហានិភ័យអាកាសធាតុ
- បង្កើតប្រព័ន្ធកសិកម្មដែលធន់នឹងអាកាសធាតុ សម្រាប់បន្សាំនឹងការប្រែប្រួលរបបទឹក ដើម្បីបង្កើនទិន្នផលដំណាំ
- លើកកម្ពស់កសិកម្មដែលធន់នឹងអាកាសធាតុនៅក្នុងតំបន់ឆ្នេរ តាមរយៈការសង់ទំនប់ការពារទឹកប្រៃ និងការពង្រីកប្រព័ន្ធកសិដ្ឋានវៃឆ្លាតចំពោះការប្រែប្រួលអាកាសធាតុ
- បង្កើតពូជដំណាំនានាដែលសមស្របនឹងតំបន់កសិ-ក្សេត្របរិស្ថាន (AEZ) និងធន់នឹងការប្រែប្រួលអាកាសធាតុ

- លើកកម្ពស់ប្រព័ន្ធផលិតកម្មវារីវប្បកម្ម និងទម្លាប់ល្អៗដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- ជួសជុល និងស្តារហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ដែលមានស្រាប់ និងធានាប្រតិបត្តិការនិងការថែទាំប្រកបដោយប្រសិទ្ធភាព ដោយគិតគូរផងដែរអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ
- ពង្រីកកម្មវិធីការពារជំងឺគ្រុនចាញ់ឆ្ពោះទៅស្ថានភាពត្រៀមលុបបំបាត់ជំងឺគ្រុនចាញ់ទាំងស្រុង
- ពង្រីកកម្មវិធីជាតិស្តីពីជំងឺប្រព័ន្ធផ្លូវដង្ហើម ជំងឺរាករូស និងអាសន្នរោគនៅក្នុងតំបន់ងាយជួបគ្រោះមហន្តរាយ ដែលរួមទាំងការឃ្លាំមើល និងការស្រាវជ្រាវអំពីជំងឺឆ្លងតាមទឹក ជំងឺឆ្លងតាមចំណីអាហារ ដែលពាក់ព័ន្ធជាមួយការប្រែប្រួលអាកាសធាតុ
- ការពង្រឹងសមត្ថភាពបច្ចេកទេស និងសមត្ថភាពស្ថាប័ន ដើម្បីវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការព្យាករពីការប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍តាមវិស័យ និងតាមអនុវិស័យ។

ការអនុវត្តសកម្មភាពនីមួយៗខាងលើ និងបរិបទនៃយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុមានបង្ហាញក្នុងតារាងទី១ នៅក្នុងឧបសម្ព័ន្ធ។

# ៣. ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់

## ៣.១ ការរួមចំណែក

ការរួមចំណែករបស់កម្ពុជា ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មានលក្ខណៈស្របគ្នាទៅនឹងលក្ខខណ្ឌមួយចំនួននៃសេចក្តីអំពាវនាវរបស់ទីក្រុង លីម៉ា (Lima Call for Action) កថាខ័ណ្ឌទី១១ ដែលមានខ្លឹមសារដូចខាងក្រោម៖

- *" ...ប្រទេសអភិវឌ្ឍន៍តិចតួច និងរដ្ឋកំពុងអភិវឌ្ឍន៍ដែលជាកូនកោះតូចៗ អាចធ្វើរបាយការណ៍ស្តីពីយុទ្ធសាស្ត្រ ផែនការ និងសកម្មភាពនានាសម្រាប់ការអភិវឌ្ឍបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិច ដែលឆ្លុះបញ្ចាំងអំពីស្ថានភាពពិសេសរបស់ខ្លួនទាក់ទងទៅនឹង របាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញា UNFCCC... "*

កម្ពុជាមានបំណងលើកស្នើនូវការចូលរួមចំណែករបស់ខ្លួន ដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់សម្រាប់ឆ្នាំ២០២០-២០៣០ ហើយការអនុវត្តនេះទាមទារឱ្យមានការគាំទ្រពីសហគមន៍អន្តរជាតិ ជាពិសេស ដោយអនុលោមតាមមាត្រាទី៤.៣ នៃអនុសញ្ញា UNFCCC។ ពិសេសទៅទៀតនោះទោះបីជាប្រទេសកម្ពុជាស្ថិតនៅក្នុងលំដាប់នៃប្រទេសអភិវឌ្ឍន៍តិចតួចក៏ដោយ ក៏កម្ពុជាកំពុងអនុវត្តសកម្មភាពនានា ស្របតាមតម្រូវការអភិវឌ្ឍដោយចីរភាពរបស់ខ្លួន ហើយក៏បានចូលរួមចំណែកដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដែលរួមមានដូចជា៖

(i) ក្នុងវិស័យឧស្សាហកម្មថាមពល ឧស្សាហកម្មកម្មន្តសាល ការដឹកជញ្ជូន និងវិស័យដទៃទៀត៖ កម្ពុជាមានបំណងអនុវត្តសកម្មភាពនានា ដូចមានចែងក្នុងតារាងទី១ ដែលការ

អនុវត្តនេះអាចចូលរួមចំណែកកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានរហូតដល់៣,១ លានតោនសមមូលឧស្ម័នកាបូនិក ធៀបនឹងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបចំនួន១១,៦ លានតោនសមមូលឧស្ម័នកាបូនិកត្រឹមឆ្នាំ២០៣០។

(ii) ក្នុងវិស័យការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ (LULUCF)៖ កម្ពុជាមានបំណងអនុវត្តសកម្មភាពដោយស្ម័គ្រចិត្ត និងដោយមានលក្ខខណ្ឌមួយចំនួន ដើម្បីសម្រេចបានតាមគោលដៅនៃការបង្កើនគម្របព្រៃឈើឱ្យបានដល់៦០% នៃផ្ទៃដីប្រទេសសរុបនៅឆ្នាំ២០៣០។ ក្នុងករណីដែលមិនបានអនុវត្តនោះ សមត្ថភាពស្រូបយកកាបូនរបស់វិស័យការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើនឹងថយចុះមកត្រឹម៧,៨៩៧លានតោនសមមូលឧស្ម័នកាបូនិក នៅឆ្នាំ២០៣០ ធៀបនឹងសមត្ថភាពនៃការស្រូបយកកាបូនតាមការប៉ាន់ស្មានរហូតដល់១៨,៤៩២លានតោនសមមូលឧស្ម័នកាបូនិក ក្នុងឆ្នាំ២០១០[6]។

តារាងទី១ និងទី២ បង្ហាញពីព័ត៌មានលំអិតស្តីពីសក្តានុពលនៃការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នៅក្នុងវិស័យទាំងនោះ ព្រមទាំងសកម្មភាពចាំបាច់មួយចំនួនដែលត្រូវអនុវត្ត ដើម្បីសម្រេចបានគោលដៅនេះ។

តារាងទី១៖ សកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងវិស័យសំខាន់ៗមួយចំនួន និងបរិមាណកាត់បន្ថយសរុបត្រឹមឆ្នាំ២០៣០

| *វិស័យ* | *សកម្មភាពជាអាទិភាព* | *បរិមាណកាត់បន្ថយគិតជាលានតោនសមមូលឧស្ម័នកាបូនិក និង (%) នៅឆ្នាំ២០៣០ ធៀបនឹងទិន្នន័យគោល* |
|---|---|---|
| ឧស្សាហកម្មថាមពល | ការផលិតថាមពលកកើតឡើងវិញដោយភ្ជាប់ទៅបណ្តាញជាតិ (ថាមពលព្រះអាទិត្យ ថាមពលវារីអគ្គិសនី ជីវៈម៉ាស និងជីវឧស្ម័ន) និងការតភ្ជាប់ស្ថានីយ៍ផលិតថាមពលតូចៗទៅបណ្តាញចែកចាយ។ អគ្គិសនីក្រៅបណ្តាញ (Off-grid) ដូចជាប្រព័ន្ធថាមពលព្រះអាទិត្យតាមគេហដ្ឋាន ថាមពលវារីអគ្គិសនី(ខ្នាតតូចៗ)។ | ១,៨ (១៦%) |

[6]ព័ត៌មាននេះបានផ្អែកលើការប៉ាន់ប្រមាណដែលបានធ្វើឡើងសម្រាប់ការរៀបចំរបាយការណ៍ជាតិលើកទី២។

| | | |
|---|---|---|
| | ការលើកកម្ពស់ប្រសិទ្ធភាពថាមពលដោយអ្នកប្រើប្រាស់ផ្ទាល់។ | |
| ឧស្សាហកម្មកម្មន្តសាល | ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញ និងអនុវត្តប្រសិទ្ធភាពថាមពលនៅតាមរោងចក្រកាត់ដេរ ម៉ាស៊ីនកិនស្រូវ និងឡឥដ្ឋ | ០,៧២៧ (៧%) |
| ការដឹកជញ្ជូន | ជំរុញប្រព័ន្ធដឹកជញ្ជូនសាធារណៈ កែលម្អប្រតិបត្តិ--ការ និងការថែទាំយានយន្តតាមរយៈការពិនិត្យយានយន្ត និងការបើកបរប្រកបដោយភាពឆ្លាតវៃ និងបង្កើនការប្រើប្រាស់រថយន្តអ៊ីប្រ៊ីដ រថយន្តអគ្គិសនីនិងទោចក្រយានយន្ត | ០,៣៩ (៣%) |
| វិស័យផ្សេងទៀត | ជំរុញការប្រើប្រាស់ប្រសិទ្ធភាពថាមពលនៅតាមអគារនិងការប្រើប្រាស់ចង្ក្រានប្រសិទ្ធភាពថាមពល កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មានប្រភពពីសំណល់តាមរយៈការប្រើប្រាស់ឡជីវឧស្ម័ននិងផុងចម្រោះ និងការប្រើប្រាស់ថាមពលកកើតឡើងវិញសម្រាប់ស្រោចស្រពដំណាំ និងចង្កៀងព្រះអា--ទិត្យ។ | ០,១៥៥ (១%) |
| ការកាត់បន្ថយសរុប | | ៣,១ (២៧%) |

តារាងទី២៖ ការរួមចំណែកទៅក្នុងវិស័យការប្រែប្រួល ការប្រើប្រាសដី និងព្រៃឈើ

| *ឈ្មោះសកម្មភាព* | *សេចក្តីអធិប្បាយ* | *បរិមាណឧស្ម័នកាត់បន្ថយ* |
|---|---|---|
| កំណើនគម្របព្រៃឈើដល់៦០% នៃផ្ទៃប្រទេសរហូតឆ្នាំ២០៣០ និងការរក្សាគម្របព្រៃឈើឱ្យនៅដដែលក្រោយ ឆ្នាំ២០៣០ | អនុលោមតាមកម្មវិធីព្រៃឈើជាតិ (២០១០-២០២៩) រាជរដ្ឋាភិបាលកម្ពុជាកំពុងប្រឹងប្រែងបង្កើន និងរក្សាគម្រប ព្រៃឈើរហូតដល់៦០% នៃផ្ទៃប្រទេសពីអត្រាប៉ាន់ស្មានប្រហែល៥៧% នៅឆ្នាំ២០១០។ ផែនការទាំងនេះរួមមាន៖ <u>ការធ្វើចំណាត់ថ្នាក់តំបន់ព្រៃឈើឡើងវិញដើម្បីបញ្ជៀសការបាត់បង់ព្រៃឈើ៖</u> | ៤,៧តោនសមមូល $CO_2$/ហ.ត./ឆ្នាំ |

| | | |
|---|---|---|
| | - តំបន់ការពារធម្មជាតិ៖ ២,៨លានហិកតា<br>- ព្រៃការពារ៖ ៣លានហិកតា<br>- សហគមន៍ព្រៃឈើ៖ ២លានហិកតា<br>- ព្រៃសម្បទានដែលត្រូវបានចាត់ថ្នាក់ឡើងវិញជាព្រៃការពារនិងព្រៃផ្តល់ផល៖ ០,៣លានហិកតា<br>- ព្រៃផលិតកម្ម៖ ២,៥លានហិកតា<br>ការអនុវត្តកម្មវិធី FLEGT នៅកម្ពុជាដែលមានគោលដៅកែលម្អអភិបាលកិច្ចព្រៃឈើនិងជម្រុញឱ្យមានការធ្វើពាណិជ្ជកម្មអន្តរជាតិនៃឈើស្របច្បាប់ដែលបានផ្ទៀងផ្ទាត់រួច។ | |

៣.២ ព័ត៌មានដើម្បីផ្ទៀងផ្ទាត់អំពីសុក្រឹតភាព តម្លាភាព និងការយោគយល់

តារាងទី៣ ផ្តល់នូវព័ត៌មានបន្ថែម ដើម្បីសម្រួលដល់លេខាធិការដ្ឋានអនុសញ្ញា UNFCCC ក្នុងការចងក្រង និងធ្វើការប្រៀបធៀបពីការរួមចំណែករបស់បណ្តាប្រទេសភាគីនៃអនុសញ្ញានេះក្នុងការអនុវត្តរបាយការណ៍ស្តីពីការចូលរួមចំណែករបស់ខ្លួន នៅក្រោមអនុវត្តអនុសញ្ញា UNFCCC។

តារាងទី៣: ព័ត៌មានសង្ខេបដើម្បីផ្ទៀងផ្ទាត់អំពីសុក្រឹតភាព តម្លាភាពនិងការយោគយល់

| ព័ត៌មានសម្រាប់លេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ | |
|---|---|
| ពេលវេលា និងរយៈពេលសម្រាប់អនុវត្ត | |
| ពេលវេលាសម្រាប់អនុវត្ត | ឆ្នាំ២០២០ដល់ ឆ្នាំ២០៣០ |
| ប្រភេទឧស្ម័ន និងវិសាលភាពគ្របដណ្តប់ | |
| ប្រភេទឧស្ម័នផ្ទះកញ្ចក់ក្នុងរបាយការណ៍ | ឧស្ម័នកាបូនិក ($CO_2$), មេតាន ($CH_4$), ឌីអាសូតម៉ូណូអុកស៊ីត ($N_2O$) |
| វិសាលភាពនៃការសិក្សាសម្រាប់ របាយ | ទូទាំងប្រទេស |

| ព័ត៌មានសម្រាប់លេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ | |
|---|---|
| ការណ៍ | |
| ការសន្មត និងអភិក្រមវិធីសាស្ត្រ | |
| វិធីសាស្ត្រសម្រាប់គណនាការបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងនិទស្សន៍ | សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់កន្លងមក៖ទិន្នន័យស្តីពី ការគណនាការបញ្ចេញ និងសមត្ថភាពស្រូបយកឧស្ម័នផ្ទះកញ្ចក់ប្រើប្រាស់ក្នុងរបាយការណ៍នេះផ្អែកលើទិន្នន័យពង្រាងរបាយការណ៍របាយការណ៍ជាតិលើកទី២ ដែលរៀបចំដោយរដ្ឋាភិបាលកម្ពុជា។ការធ្វើសារពើភ័ណ្ឌ ឧស្ម័នផ្ទះកញ្ចក់នេះប្រើប្រាស់វិធីសាស្ត្រលំដាប់ទី១ ដែលចែងក្នុងគោលការណ៍ណែនាំរបស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC 1996), មេគុណបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីការប្រែប្រួលអាកាសធាតុ និងទិន្នន័យជាក់ស្តែងមួយចំនួនរបស់ប្រទេសពីឆ្នាំ២០០០។<br>ការប៉ាន់ស្មាននៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់គោល៖នៅក្នុងវិស័យថាមពល ការប៉ាន់ស្មាននៅក្នុងរបាយការណ៍ជាតិលើកទី២ប្រើប្រាស់ម៉ូដែលផែនការថាមពលរយៈពេលវែង (LEAP) ដោយប្រើប្រាស់មេគុណបញ្ចេញជំនួស និងទិន្នន័យជាក់ស្តែងមកពីប្រភពខុសៗគ្នាជាច្រើន។ ការប៉ាន់ស្មានសម្រាប់ វិស័យប្រើប្រាស់ដីការប្រែប្រួលការប្រើប្រាស់ដីនិងព្រៃឈើ (LULUCF) រួមបញ្ចូលទាំងការ បម្លែងគម្របព្រៃឈើ និងវាលស្មៅ និងដីធ្លីទំនេរ ហើយការគណនានេះផ្អែកលើវិធីសាស្ត្រនានានៅក្នុងគោលការណ៍ណែនាំរបស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC)។ រាល់ការប៉ាន់ស្មានទាំងអស់បានគិតគូរដល់ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនយោបាយ និងទីផ្សារ និងស្ថានភាពផ្សេងៗទៀតនៅក្នុងវិស័យដទៃ។<br>ជម្រើសកាត់បន្ថយ៖ ជម្រើសទាំងនេះត្រូវបានរៀបចំឡើងដោយផ្អែកលើការវិភាគកន្លងមក បទពិសោធន៍ពីគម្រោង |

| ព័ត៌មានសម្រាប់លេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ | |
|---|---|
| | ដែលទទួលបានដោតជ័យគម្រោងសាកល្បង ការសិក្សាវាយតម្លៃឯកសារស្រាវជ្រាវ និងយោបល់ពីអ្នកជំនាញការនានា។ |
| វិធីសាស្រ្តនានាសម្រាប់ការគណនាការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការប្រើប្រាស់ការប្រែប្រួលការប្រើប្រាស់ដីនិងព្រៃឈើ | ទោះបីសកម្មភាពដែលប្រើប្រាស់ក្នុងវិស័យការប្រើប្រាស់ការប្រែប្រួលការប្រើប្រាស់ដីនិងព្រៃឈើត្រូវបានអនុវត្តដោយមានលក្ខខណ្ឌក៏ដោយ ក៏តារាងបង្ហាញពីសកម្មភាពជាក់ស្តែង និងលទ្ធផលនៃការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នឹងត្រូវធ្វើបច្ចុប្បន្នភាពនៅពេលបញ្ចប់យុទ្ធសាស្រ្ត REDD+។ |
| សក្តានុពលកំដៅសកល (GWP) | តួលេខសក្តានុពលកំដៅសកល ដែលប្រើប្រាស់សម្រាប់គណនាសមមូលឧស្ម័នកាបូនិក ត្រូវបានស្រង់ចេញពីរបាយការណ៍វាយតម្លៃលើកទី២ របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| ចំណុចយោង | |
| ការបញ្ចេញក្រោមលក្ខខណ្ឌធម្មតាដែលមិនគិតពីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (BAU) នៅក្នុងឆ្នាំគោលដៅ | ១១,៦ លានតោនសមមូលឧស្ម័នកាបូនិក ត្រឹមឆ្នាំ២០៣០ |
| វិធីសាស្រ្តធ្វើការប៉ាន់ស្មានសម្រាប់សេណារីយ៉ូកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ | ម៉ូដែល LEAP ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការប៉ាន់ស្មានសេណារីយ៉ូធម្មតាសម្រាប់វិស័យថាមពលចំណែកម៉ូដែល COMAP ត្រូវបានប្រើប្រាស់សម្រាប់ វិស័យការប្រើប្រាស់ការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ ដូចមានបង្ហាញក្នុងសេចក្តីព្រាងរបាយការណ៍ជាតិលើកទី២។ |

## ៣.៣ ភាពត្រឹមត្រូវ និងមហិច្ឆិតា

កម្ពុជាជាទទួលស្គាល់ពីភាពចាំបាច់ឱ្យប្រទេសទាំងអស់បង្ហាញពីរបាយការណ៍ជាតិស្តីពីការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញា UNFCCC ឱ្យបានត្រឹមត្រូវ និងមានមហិច្ឆិតាខ្ពស់ក្នុងការកាត់បន្ថយការ

បញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដើម្បីឆ្លើយតបនឹងគោលបំណង ដូចមានចែងក្នុងសេចក្តីអំពាវនាវនៅក្រុងលីម៉ា។

ក្នុងឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចមួយ កម្ពុជាមានចំណែកតិចតួចនៅក្នុងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សកល នាពេលបច្ចុប្បន្ន ដែលត្រូវជាមួយភាគតូចនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់លើពិភពលោកក្នុងពេលកន្លងមក។ ដោយពិចារណាអំពីតួនាទីសំខាន់នៃព្រៃឈើក្នុងការស្រូបយកកាបូន កម្ពុជានៅតែមានតុល្យភាពជាប្រទេសស្រូបកាបូននៅក្នុងឆ្នាំ២០០០។ តាមការប៉ាន់ស្មាននៅក្នុងសេចក្តីព្រាងរបាយការណ៍ជាតិលើកទី២ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងមនុស្សម្នាក់ៗនៅកម្ពុជាក្នុងលក្ខខណ្ឌទម្លាប់ធម្មតា នៅឆ្នាំ២០៥០នឹងមាន២,៥៩តោនសមមូលឧស្ម័នកាបូនិក ដែលតួលេខនេះទាបជាងពាក់កណ្តាលនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងមនុស្សម្នាក់ៗនាពេលបច្ចុប្បន្នលើពិភពលោក។ សកម្មភាពដែលបានស្នើ ប្រសិនបើបានទទួលការគាំទ្រគ្រប់គ្រាន់តាមរយៈហិរញ្ញវត្ថុ បច្ចេកវិទ្យា និងការកសាងសមត្ថភាព នឹងរក្សាកម្រិតបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងមនុស្សម្នាក់ៗត្រឹម២,០៤តោនសមមូលឧស្ម័នកាបូនិករហូតឆ្នាំ២០៣០ ដែលនៅទាបជាងតួលេខមធ្យមភាគលើពិភពលោក សម្រាប់ទប់កំណើនសីតុណ្ហភាពមិនឱ្យលើសពី២$^{o}$C។

ទោះបីនៅជាប្រទេសអភិវឌ្ឍន៍តិចតួចក៏ដោយ ក៏កម្ពុជាបានបង្ហាញជូនជាលើកដំបូងនូវតារាងស្តីពីសកម្មភាពកាត់បន្ថយបញ្ចេញឧស្ម័នផ្ទះកញ្ចក់ច្បាស់លាស់មួយដើម្បីកំណត់កំណើននៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន ដែលធ្វើឱ្យមានភាពខុសគ្នាជាច្រើនធៀបនឹងសេណារីយ៉ូតាមទម្លាប់ធម្មតា (BAU) មានន័យថាខ្លួនមានបំណងធ្វើអ្វីលើសពីសកម្មភាពកំពុងអនុវត្តស្រាប់។

កម្ពុជាប្រឹងប្រែងបង្កើនជាអតិបរមានូវភាពបំពេញគ្នារវាងការកាត់បន្ថយ និងការបន្សាំជាមួយនឹងការអភិវឌ្ឍដោយចីរភាព។ ដូច្នេះ សកម្មភាពនានាដែលបានស្នើឡើងត្រូវតែធ្វើសមាហរណកម្មជាមួយអាទិភាពនៃការអភិវឌ្ឍរបស់កម្ពុជា ដែលធានាថា កំណើនសេដ្ឋកិច្ចឆ្ពោះទៅរកលំនាំនៃការអភិវឌ្ឍដែលបញ្ចេញកាបូនតិចនិងបន្សុីគ្នាជាមួយកិច្ចប្រឹងប្រែងនានាដើម្បីបង្កើនភាពធន់នឹងអាកាសធាតុរបស់ប្រទេសយើង។

## ៤. ដំណើរការរៀបចំផែនការនិងការអនុវត្ត

របាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញា UNFCCC ត្រូវបានរៀបចំឡើងនៅក្រោមការសម្របសម្រួលរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ក្រុមអ្នករៀបចំរបាយការណ៍នេះត្រូវបានរៀបចំឡើង ដោយមានតំណាងមកពីក្រសួងពាក់ព័ន្ធ ដែលនឹងទទួលខុសត្រូវលើការអនុវត្តសកម្មភាពជាក់លាក់។

របាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC នេះ (និងការកែសម្រួលទៅអនាគត) គឺជាផ្នែករួមមួយនៃនិម្មាបនកម្មប្រែប្រួលអាកាសធាតុកម្ពុជា។ ដូច្នេះការ

អនុវត្តនឹងត្រូវបន្សុីគ្នាជាមួយនឹងគោលនយោបាយប្រែប្រួលអាកាសធាតុជាតិកម្ពុជា និងមិនធ្វើឱ្យមានភាពត្រួតគ្នានោះឡើយ។

មានផែនការមួយចំនួនដែលមានស្រាប់នឹងអាចជួយគាំទ្រដល់កាពិនិត្យគោលនយោបាយប្រែប្រួលអាកាសធាតុកម្ពុជា សំដៅសម្រួលដល់ការអនុវត្តឱ្យបានជោគជ័យនូវរាល់សកម្មភាពនានា ដែលមានចែងក្នុងរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញា UNFCCC នេះ។ ជាការច្បាស់ណាស់ថា យុទ្ធសាស្ត្រ និងផែនការទាំងនេះនឹងត្រូវកែសម្រួលផងដែរនៅពេលដែលផុតសុពលភាព ក្រោយពីបានវាយតម្លៃលើវឌ្ឍនភាពដែលបានសម្រេចនៅក្រោមយុទ្ធសាស្ត្រ និងផែនការទាំងនោះ។

នៅក្នុងទសវត្សរ៍កន្លងទៅនេះ កម្ពុជាធ្វើឱ្យសម្រេចបាននូវវឌ្ឍនភាពច្រើនក្នុងការរៀបចំដំណើរការនានាសម្រាប់អនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-១៨) ដែលជាផែនការអភិវឌ្ឍន៍ប្រទេសទាំងមូល ចែងពីសារៈសំខាន់នៃការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (២០១៤-២០២៣) និងរួមមានសូចនាករនានាដើម្បីតាមដានទៅលើការអនុវត្តសកម្មភាពប្រែប្រួលអាកាសធាតុ។ លើសពីនេះ ការរៀបចំរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC បានប្រព្រឹត្តទៅអនុលោមផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតង(២០០៩)ដែលបានរៀបចំឡើង ក្នុងគោលដៅគាំទ្រកម្ពុជាទៅជាប្រទេសមានប្រាក់ចំណូលមធ្យមនៅឆ្នាំ២០៣០។ផែនការបង្ហាញផ្លូវនេះក៏ចែងពីគម្រោងអាទិភាពសម្រាប់រយៈពេលវែងផងដែរ ពោលគឺឆ្នាំ២០២០-២០៣០។

កម្ពុជាមានបំណងគាំទ្រដល់ការអនុវត្តជំហានដំបូងនៃ របាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC ជាពិសេសតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ (ផ.យ.ប.អ.ក.)។ បណ្តាអាទិភាពជាយុទ្ធសាស្ត្រខាងក្រោមមានគោលដៅអភិវឌ្ឍន៍ប្រទេសកម្ពុជាឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល៖

(១) ក្រសួងពាក់ព័ន្ធបានរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងផែនការសកម្មភាពតាមវិស័យ (ផ.យ.ប.អ. តាមវិស័យ និងផ.ស.ប.អ. តាមវិស័យ) ដោយបានបន្សុីគ្នាជាមួយ ផ.យ.ប.អ.ក. និងគ្របដណ្តប់វិស័យសំខាន់ៗដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលមានចែងនៅក្នុងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ NAPA និង របាយការណ៍ជាតិក្រោមអនុសញ្ញា UNFCCC។ កម្ពុជាក៏ធ្វើការបញ្ជ្រាបភាពធន់នឹងការប្រែប្រួលអាកាសធាតុទៅក្នុងប្រព័ន្ធរៀបចំផែនការ និងហិរញ្ញប្បទាននៅថ្នាក់ក្រោមជាតិផងដែរ។

(២) ចំពោះការបន្សាំ កម្ពុជាបានអនុវត្តកិច្ចផ្តួចផ្តើមនានាដើម្បីបញ្ជ្រាបការបន្សាំទៅក្នុងការអភិវឌ្ឍជាតិ និងវិស័យជាក់លាក់ដូចជា វិស័យកសិកម្ម ព្រៃឈើ និងសុខភាពមនុស្ស ក៏ដូចជាការគ្រប់គ្រងតំបន់ឆ្នេរផងដែរ។ បន្ថែមលើផ.យ.ប.អ.ក. ផ.យ.ប.អ. តាមវិស័យ និងផ.ស.ប.អ. តាមវិស័យ កម្ពុជាបានរៀបចំ កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (២០០៦) ដែលក្នុងនោះយន្តការទាំងដើម្បីដោះស្រាយផលប៉ះពាល់ និងគ្រោះថ្នាក់ពីការប្រែប្រួលអាកាសធាតុ ក៏ដូចជាតម្រូវការបន្សាំសំខាន់ៗ ត្រូវបានកំណត់។

(៣) កម្ពុជាកំពុងអនុវត្ត ដំណើរការរៀបចំផែនការបន្សាំជាតិ (NAP) ដើម្បីពង្រឹងដល់ដំណើរការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការរៀបចំកម្មវិធីអន្តរវិស័យ និងការអនុវត្ត ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ NAP អាចផ្តល់ជាព័ត៌មានសម្រាប់រៀបចំយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅអនាគតក្របខ័ណ្ឌហិរញ្ញប្បទាននិងការរៀបចំផែនការអភិវឌ្ឍន៍ជាតិនិងការលើកគម្រោងថវិកាផងដែរ។

(៤) សកម្មភាពដែលទាក់ទងនឹងព្រៃឈើនឹងត្រូវអនុវត្តជាផ្នែកមួយនៃយុទ្ធសាស្ត្រ REDD+។ កម្ពុជាកំពុងរៀបចំប្រព័ន្ធពិនិត្យតាមដានព្រៃឈើ (NFMS) ថ្នាក់ជាតិ និងកំណត់កម្រិតបញ្ចេញឧស្ម័នផ្ទះកញ្ចក់គោល សំដៅកំណត់ឱ្យបានជាក់លាក់នូវផលប៉ះពាល់នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីសកម្មភាពនានានៃវិស័យនេះ។ កិច្ចការនេះនឹងបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្ត និងការគណនាសម្រាប់សកម្មភាពក្នុងវិស័យព្រៃឈើនៅក្រោយឆ្នាំ២០២០។ លើសពីនេះ កម្រិតនៃការបញ្ចេញឧស្ម័នគោលពីព្រៃឈើ/កម្រិតយោងព្រៃឈើ (FREL/FRL) និងប្រព័ន្ធព័ត៌មានអំពីកិច្ចការពារសុវត្ថិភាព (SIS) ក៏នឹងត្រូវប្រើប្រាស់សម្រាប់គណនាបរិមាណនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបានកាត់បន្ថយតាមរយៈការអនុវត្តសកម្មភាពដែលបានកំណត់សម្រាប់ឆ្នាំ២០១៦-២០២០។

កម្ពុជាបានរៀបចំជាជំហានៗដើម្បីធានាថា ប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃរបស់ខ្លួនមានបញ្ចូលសូចនាករនានាសម្រាប់វាស់វែងវឌ្ឍនភាព ដែលរួមទាំងការអនុវត្តរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC សម្រាប់ការបន្សាំ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់ MRV នឹងរៀបចំឡើងដោយផ្អែកលើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់។ ដោយឡែក ការបន្តគាំទ្រដល់ការរៀបចំប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់ MRV សម្រាប់ REDD+ គឺជាតម្រូវការចាំបាច់ ដើម្បីអាចឱ្យកម្ពុជាឈានទៅរកដំណាក់កាលទីបីនៃ REDD+ ដែលកម្ពុជានឹងអាចទទួលការបង់ថ្លៃដែលផ្អែកលើលទ្ធផល។ បច្ចុប្បន្នប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ការបន្សាំកំពុងស្ថិតក្នុងការអនុវត្តនៅកម្រិតគម្រោង។ ក្របខ័ណ្ឌប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃនៅថ្នាក់ជាតិនឹងត្រូវរៀបចំចំណែកសកម្មភាពនានាដើម្បីដាក់ឱ្យអនុវត្តក្របខ័ណ្ឌនេះនៅក្នុងវិស័យគន្លឹះនានា ក៏បានចាប់ផ្តើមរួចមកហើយផងដែរ។

តារាងនៅក្នុងឧបសម្ព័ន្ធមានសង្ខេបអំពីសកម្មភាពជាអាទិភាពអំពីការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងដំណើរការដែលបានស្នើឡើងទាក់ទងនឹងការរៀបចំផែនការ និង

ការអនុវត្ត។ ការពិចារណាអំពីវឌ្ឍនភាព និងមេរៀននានាត្រូវបានរំពឹងថា នឹងធ្វើឡើងនៅឆ្នាំ ២០១៨ ដើម្បីការរៀបចំផែនការសកម្មភាពសម្រាប់អំឡុងពេលបន្ត។

## ៥. មធ្យោបាយនៃការអនុវត្ត

កម្ពុជាត្រូវការគាំទ្រតាមផ្នែកហិរញ្ញវត្ថុ ការកសាងសមត្ថភាព និងការផ្ទេរបច្ចេកវិទ្យា ដើម្បីអនុវត្តសកម្មភាពដែលមានចែងនៅក្នុងរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC នេះ។ ការវិភាគពិស្តារនៅពេលចាប់ផ្តើមអនុវត្តរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC មានសារៈសំខាន់ណាស់ ដើម្បីបន្សុីគ្នាជាមួយសកម្មភាពនៃផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងកែលម្អការប៉ាន់ប្រមាណអំពីតម្រូវការមូលនិធិ ជាពិសេសនៅក្រោយឆ្នាំ២០១៨។ ការវិភាគនេះនឹងកំណត់បាននូវប្រភេទ និងកម្រិតជាក់លាក់នៃការគាំទ្រ ដែលត្រូវការជាចាំបាច់ ជាពិសេសទាក់ទងនឹងការកសាងសមត្ថភាព និងការផ្ទេរបច្ចេកវិទ្យា។

ការវាយតម្លៃអំពីតម្រូវការគាំទ្រនឹងផ្អែកលើក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុដែលបានរៀបចំឡើងជាមួយផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ក្របខណ្ឌនេះរាប់បញ្ចូលទាំងការវិភាគអំពីប្រភពហិរញ្ញប្បទាន ការកំណត់ថ្លៃចំណាយ ការវិភាគផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើសេដ្ឋកិច្ច និងអនុសាសន៍នានាអំពីគំរូហិរញ្ញប្បទានទាំងឡាយសម្រាប់ការអនុវត្ត ផ.យ.ប.អ.ក.។

យោងតាមការវាយតម្លៃតម្រូវការហិរញ្ញវត្ថុ សម្រាប់សកម្មភាពអាទិភាព ដែលមាននៅក្នុងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ កម្ពុជាត្រូវការថវិកា១,២៧៣ាន់លានដុល្លារអាមេរិកសម្រាប់គាំទ្រការអនុវត្តបណ្តាសកម្មភាពទាំងនោះ ត្រឹមឆ្នាំ២០១៨។ ការវាយតម្លៃនេះក៏បានគិតគូរផងដែរអំពីសមត្ថភាពស្រូបយករបស់កម្ពុជាដើម្បីធានាថា ការវិនិយោគដែលស្នើឡើងមានប្រសិទ្ធិភាព។

ការគាំទ្រហិរញ្ញវត្ថុអន្តរជាតិគឺជាការបំពេញបន្ថែមលើអ្វីដែលកម្ពុជាកំពុងធ្វើវិភាជន៍ ដើម្បីអនុវត្តផែនការអភិវឌ្ឍន៍ដោយចីរភាពរបស់ខ្លួន និងសម្រេចបាននូវមានផលប៉ះពាល់វិជ្ជមាននៃសកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ បានប៉ាន់ប្រមាណថា នៅឆ្នាំ២០១២ ការចំណាយនេះមាន៦,៥% នៃការចំណាយសរុបក្នុងវិស័យសាធារណៈ ឬត្រូវជា១,៣១% នៃផលទុនក្នុងស្រុកសរុប (ផ.ស.ស.)។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មានបញ្ជាក់ពីការបង្កើនអត្រានៃការចំណាយលើការងារអាកាសធាតុ ធៀបនឹងផ.ស.ស. ដែលប៉ាន់ស្មានពី ១,៣៩%នៅឆ្នាំ២០១៥ ដល់១,៥% នៅឆ្នាំ២០១៨។

ការគាំទ្រហិរញ្ញវត្ថុអន្តរជាតិនឹងធ្វើឡើង តាមរយៈយន្តការទ្វេភាគី និងពហុភាគី ក៏ដូចជាយន្តការទីផ្សារផងដែរ។ កម្ពុជាកំពុងសម្រេចបាននូវវឌ្ឍនៈភាពច្រើនលើការត្រៀមលក្ខណៈសម្រាប់ការទទួលបានដោយផ្ទាល់នូវមូលនិធិអាកាសធាតុបៃតង (GCF) ដែលអាចក្លាយជាមធ្យោបាយចំបងមួយសម្រាប់ហិរញ្ញវត្ថុអាកាសធាតុទៅអនាគត។ ការផ្តល់មូលនិធិដែលផ្តោតលើកិច្ចការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុពីប្រភពអន្តរជាតិ ទាំងពីប្រភពទ្វេភាគី/ពហុភាគី ឬតាមរយៈមូលនិធិអាកាសធាតុពិភពលោកនានា តំណាងឱ្យត្រឹមតែ៤០% នៃការវិនិយោគសរុបដែលទាក់ទងនឹងអាកាសធាតុ។ យុទ្ធសាស្ត្រនេះនឹងផ្តោតផងដែរលើមូលនិធិអភិវឌ្ឍន៍ផ្សេងទៀតដែលមាន ដោយសារភាគចំណែកនៃមូលនិធិទាំងនេះដែលទាក់ទងនឹងអាកាសធាតុ ពីប្រភពក្នុងប្រទេសនិងអន្តរជាតិ គឺជាការគាំទ្រហិរញ្ញប្បទានដ៏សំខាន់។ កម្ពុជាក៏បានចូលរួមរួចមកហើយនៅក្នុងយន្តការ REDD+ សម្រាប់ការងារពាក់ព័ន្ធនឹងវិស័យព្រៃឈើ។

ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យក៏មានបញ្ជាក់អំពីតម្រូវការកសាងសមត្ថភាព។ តាមរយៈការពិគ្រោះយោបល់នានា ដែលបានធ្វើឡើងសម្រាប់ការរៀបចំរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC ការរៀបចំប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់ និងប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃត្រូវបានកំណត់ជាអាទិភាព។ ដូចដែលមានបញ្ជាក់ខាងលើ ការងារនេះបានចាប់ផ្តើមរួចមកហើយ ប៉ុន្តែនៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីរៀបចំប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់ ដោយផ្អែកលើសូចនាករដែលបានកំណត់។

កម្ពុជាបានធ្វើការវាយតម្លៃអំពីតម្រូវការបច្ចេកវិទ្យាសម្រាប់ការបន្ស៊ាំ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ហើយតម្រូវការបច្ចេកវិទ្យាក៏បង្ហាញច្បាស់ផងដែរនៅក្នុងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ។នៅពេលចាប់ផ្តើមដំណាក់កាលអនុវត្តរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC កម្ពុជាក៏នឹងត្រូវធ្វើការវាយតម្លៃពិស្តារអំពីតម្រូវការបច្ចេកវិទ្យាផងដែរ។

**ឧបសម្ព័ន្ធ៖** ព័ត៌មានបន្ថែម ដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រ និងគោលនយោបាយ ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ

កម្ពុជាមានបំណងគាំទ្រដល់ការអនុវត្តរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC ក្នុងដំណាក់កាលដំបូង តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុកម្ពុជា (ផ.យ.ប.អ.ក.) (២០១៤-២០២៣) (សូមអានតារាងទី១ខាងក្រោម)តាមរយៈអាទិភាពជាយុទ្ធសាស្ត្រក្នុងគោលដៅអភិវឌ្ឍន៍ឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល។

ទឹសដៅជាយុទ្ធសាស្ត្រនៃ ផ.យ.ប.អ.ក. រួមមាន៖

- លើកកម្ពស់ភាពធន់នឹងអាកាសធាតុតាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និងថាមពល
- កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាព នៅចំពោះមុខផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុ
- លើកកម្ពស់ភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប ។ល។) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌
- លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព
- កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ
- លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមតាមបែបបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយការបាត់បង់ និងការខូចខាត
- ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួល សម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ
- ពង្រឹងកិច្ចសហការ និងការចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់តំបន់ និងពិភពលោក។

ផ.យ.ប.អ.ក. ចែងពីយុទ្ធសាស្ត្រ និងសកម្មភាពនានាសម្រាប់ដំណាក់កាលខុសៗគ្នា ដូចតទៅ៖

- នៅក្នុងរយៈពេលខ្លី (២០១៣-២០១៤)៖ ផ្តោយលើការពង្រឹងស្ថាប័ន ការកៀរគរហិរញ្ញវត្ថុសម្រាប់អនុវត្ត ផ.យ.ប.អ.ក. ការបង្កើតក្របខ័ណ្ឌជាតិសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃ (M&E) និងសូចនាករ និងការរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់រយៈពេលមធ្យម (២០១៤-២០១៨) ដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ
- នៅក្នុងរយៈពេលមធ្យម (២០១៤-២០១៨)៖ ប្រកាសចាប់ផ្តើមកម្មវិធីដែលមានអាទិភាពខ្ពស់ ជាមួយការផ្តោតដំបូងលើការបន្សាំ ហើយបន្តិចម្តងៗនឹងគាំទ្រការពង្រីកសកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ការរៀបចំយន្តការទទួលបានមូលនិធិបន្សាំ និងមូលនិធិអាកាសធាតុបៃតង
- នៅក្នុងរយៈពេលវែង (២០១៩-២០២៣) ផ្តោតលើការស្រាវជ្រាវ និងរៀនសូត្រប៉ុន្តែគោលដៅចំបងនៃដំណាក់កាលនេះគឺពង្រីកកិច្ចផ្តួចផ្តើមជោគជ័យទាំងឡាយដែលសម្រេច បានកន្លងមក និងបន្តបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

តារាងទី១៖ ដំណើរការរៀបចំផែនការ និងការអនុវត្តរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC និងទំនាក់ទំនងជាមួយយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

| សកម្មភាពជាអាទិភាព | យុទ្ធសាស្ត្រ និងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប់ |
|---|---|
| *ការបន្សាំ* | |
| លើកកម្ពស់ និងបង្កើនសមត្ថភាពបន្សាំរបស់សហគមន៍នានា និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់បរិស្ថាន និងតំបន់ការពារធម្មជាតិឆ្នាំ២០១៤-២០១៨ |
| ការអនុវត្តវិធានការនានានៃការគ្រប់គ្រង និងការពារតំបន់នានាដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុ | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់បរិស្ថាន និងតំបន់ការពារធម្មជាតិ (២០១៤-២០១៨) |

| សកម្មភាពជាអាទិភាព | យុទ្ធសាស្ត្រ និងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប់ |
|---|---|
| ការពង្រឹងប្រព័ន្ធព័ត៌មានអាកាសធាតុ និងប្រព័ន្ធប្រកាសផ្តល់ព័ត៌មានជាមុន | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ធនធានទឹក និងឧតុនិយម(២០១៤-២០១៨) |
| ការកសាង និងជួសជុលទំនប់ការពារទឹកជំនន់សម្រាប់វិស័យ កសិកម្ម និងការអភិវឌ្ឍទីប្រជុំជន | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការ ប្រែប្រួលអាកាសធាតុសម្រាប់ធនធានទឹកនិងឧតុនិយម(២០១៤-២០១៨) |
| ការបង្កើនការប្រើប្រាស់ស្ថានីយ៍បូមទឹកចល័ត និងស្ថានីយ៍អចិន្ត្រៃយ៍ក្នុងការឆ្លើយតបទៅនឹងភាពរាំងស្ងួតក្នុងកូនរដូវប្រាំងនិងជំរុញការស្រាវជ្រាវពីទឹកក្រោមដីជាការឆ្លើយតបនឹងគ្រោះរាំងស្ងួត និងហានិភ័យអាកាសធាតុ | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ធនធានទឹកនិងឧតុនិយម(២០១៤-២០១៨) |
| ការបង្កើតប្រព័ន្ធស្រោចស្រពដែលធន់នឹងអាកាសធាតុនៅថ្នាក់សហគមន៍ដើម្បីបង្កើនទិន្នផលស្រូវ និងផលិតកម្មកសិកម្ម | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការណប្រែប្រួលអាកាសធាតុសម្រាប់ការអភិវឌ្ឍជនបទ (២០១៤-២០១៨) |
| ការលើកកម្ពស់កសិកម្មដែលធន់នឹងអាកាសធាតុតាមរយៈការសាងសង់ទំនប់ការពារទឹកប្រៃក្នុងតំបន់ឆ្នេរនិងពង្រីកប្រព័ន្ធកសិដ្ឋានវៃឆ្លាតចំពោះការប្រែប្រួលអាកាសធាតុ | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការ ប្រែប្រួលអាកាសធាតុសម្រាប់ធនធានទឹក និងឧតុនិយម(២០១៤-២០១៨) និងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្ម ព្រៃឈើ និងនេសាទ (២០១៤-២០១៨) |
| ការបង្កើតពូជដំណាំនានាដែលសមស្របនឹងតំបន់ក្សេត្របរិស្ថាន (AEZ) និងធន់នឹងការប្រែប្រួលអាកាសធាតុ (រួមទាំងតំបន់ឆ្នេរ) | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្មព្រៃឈើ និងនេសាទ (២០១៤-២០១៨) |
| លើកកម្ពស់ប្រព័ន្ធផលិតកម្មវារីវប្បកម្ម និងទម្លាប់ប្រតិបត្តិដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុ | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការ ប្រែប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្មព្រៃឈើ និងនេសាទ (២០១៤-២០១៨) |
| ការជួសជុល និងស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដែលមានស្រាប់ និងធានាប្រតិបត្តិការនិងការថែទាំ | ការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យសាធារណ |

| សកម្មភាពជាអាទិភាព | យុទ្ធសាស្ត្រ និងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប់ |
|---|---|
| ដោយប្រសិទ្ធភាព ដោយគិតគូរផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | ការនិងដឹកជញ្ជូន(២០១៤-២០១៨) |
| ការពង្រីកកម្មវិធីត្រួតពិនិត្យការពារជំងឺគ្រុនចាញ់ឆ្ពោះទៅស្ថានភាពត្រៀមលុបបំបាត់ជំងឺគ្រុនចាញ់ទាំងស្រុង | ការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យសុខភាពសាធារណៈ (២០១៤-២០១៨) |
| ការពង្រីកកម្មវិធីជាតិស្តីពីជំងឺប្រព័ន្ធផ្លូវដង្ហើមធ្ងន់ធ្ងរ ជំងឺរាគរូស និងអាសន្នរោគ នៅក្នុងតំបន់ងាយមានគ្រោះមហន្តរាយ រួមទាំងការឃ្លាំមើល និងការស្រាវជ្រាវអំពីជំងឺឆ្លងតាមទឹកនិងជំងឺឆ្លងតាមអាហារដែលពាក់ព័ន្ធជាមួយការប្រែប្រួលអាកាសធាតុ | ការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យសុខភាពសាធារណៈ (២០១៤-២០១៨) |
| ការពង្រឹងសមត្ថភាពបច្ចេកទេស និងស្ថាប័នដើម្បីធ្វើការវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុការព្យាករពីការប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍តាមវិស័យនិងតាមអនុវិស័យ | ការអនុវត្តអនុសាសន៍ពីសេចក្តីព្រាងរបាយការណ៍ជាតិលើកទី២ |
| *ការកាត់បន្ថយ* | |
| <u>ឧស្សាហកម្មថាមពល</u><br>ការតភ្ជាប់អគ្គិសនីដែលផលិតពីថាមពលកកើតឡើងវិញជាមួយបណ្តាញ (ថាមពលព្រះអាទិត្យ វារីអគ្គិសនី ជីវៈម៉ាស និងជីវឧស្ម័ន) និងការតភ្ជាប់អ្នកផលិតសម្រាប់ការប្រើប្រាស់ ផ្ទាល់ខ្លួនទៅនឹងបណ្តាញចែកចាយ<br><br>ការផលិតអគ្គិសនីក្រៅបណ្តាញ ដូចជាប្រព័ន្ធផលិតអគ្គិសនីដោយពន្លឺព្រះអាទិត្យតាមផ្ទះ<br><br>ការជម្រុញប្រសិទ្ធភាពថាមពលក្នុងចំណោមអ្នក | ការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ឧស្សាហកម្មកម្មន្តសាល និងវិស័យថាមពល (២០១៤-២០១៨) |

| សកម្មភាពជាអាទិភាព | យុទ្ធសាស្ត្រ និងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប់ |
|---|---|
| ប្រើប្រាស់ផ្ទាល់ | |
| <u>ឧស្សាហកម្មកម្មន្តសាល</u><br>ការកាត់បន្ថយការបញ្ចេញឧស្ម័នពីដំណើរការកិនស្រូវ រោងចក្រកាត់ដេរ និងការផលិតឥដ្ឋ | ការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ឧស្សាហកម្មកម្មន្តសាល និងវិស័យថាមពល (២០១៤-២០១៨) |
| <u>វិស័យដឹកជញ្ជូន</u><br>ការត្រួតពិនិត្យយានយន្តការដឹកជញ្ជូនសាធារណៈ និងការកែលម្អប្រសិទ្ធភាពនៃយានយន្ត | ការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យដឹកជញ្ជូន (២០១៤-២០១៨) |
| <u>វិស័យដទៃទៀត</u><br>ចង្ក្រានប្រសិទ្ធភាព ឡជីវៈឧស្ម័ន ធុងចម្រោះ | ការអនុវត្តផែនការសកម្មភាព ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ឧស្សាហកម្មន្តសាលនិងវិស័យថាមពល(២០១៤-២០១៨) |
| <u>វិស័យព្រៃឈើ</u><br>ការបង្កើនគម្របព្រៃឈើដល់៦០%នៃផ្ទៃប្រទេស និងការរក្សាអត្រានេះចាប់ពីឆ្នាំ២០៣០ តទៅ | ការអនុវត្តកម្មវិធីព្រៃឈើជាតិឆ្នាំ២០១០-២០២៩ ការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្ម ព្រៃឈើនិងនេសាទ (២០១៤-២០១៨) យុទ្ធសាស្ត្រ REDD+ |

រៀបចំដោយ

ឧបត្ថម្ភដោយ

GEF

UNEP

British Embassy
Phnom Penh